**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា **លោកវេជ្ជបណ្ឌិត តឹក ប៊ុនស្រេង** ដែលត្រូវជាឪពុកបង្កើត **លោកជំទាវ តឹក កុសុនា** អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា នៃក្រសួងមុខងារសាធារណៈ និងជាឪពុកក្មេក **ឯកឧត្តម ស៊ុង វិនទិ** នាយករងសាលាភូមិន្ទរដ្ឋបាល បានទទួលមរណភាពនៅថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១:០០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ៧៤ឆ្នាំ ដោយរោគាពាធ។

**ឯកឧត្តម ខេង គី** អនុរដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនឹងដឹកនាំប្រតិភូអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទីព្រឹក នៅក្នុងបរិវេណវត្តទួលទំពូង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។
**ឯកឧត្តម ស៊ុង វិនទិ "Sung Vinntik"** មានគណនី ABA Bank ៖ 000 555 684

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ៧៨

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

## សាររំលែកមរណទុក្ខ

ជម្រាបជូន

**លោកជំទាវ តឹក កុសុម្ភា អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រង មន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា និងឯកឧត្តម ស៊ុង វិនទិ ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ លោកវេជ្ជបណ្ឌិត តឹក ប៊ុនស្រេង**

**លោកជំទាវ និងឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **លោកវេជ្ជបណ្ឌិត តឹក ប៊ុនស្រេង** ដែលជាឪពុកបង្កើតរបស់លោកជំទាវ បានទទួលមរណភាព នៅថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១:០០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ ៧៤ឆ្នាំ ដោយរោគាពាធ ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **លោកជំទាវ និងឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **លោកវេជ្ជបណ្ឌិត តឹក ប៊ុនស្រេង** ដែលជាឪពុកបង្កើត ជាឪពុកក្មេក និងជាជីតាប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **លោកជំទាវ និងឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** និងសូមឧទ្ទិសបួងសួងចំពោះដួងវិញ្ញាណក្ខន្ធរបស់ **លោកវេជ្ជបណ្ឌិត តឹក ប៊ុនស្រេង** សូមលោកបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ និងឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

រដ្ឋមន្ត្រី

ព្រុំ សុខា